## CLOSING ADDRESS

## BY SAMDECH AKKA MOHA PONHEA CHAKREI HENG SAMRIN, PRESIDENT OF THE NATIONAL ASSEMBLY OF THE KINGDOM OF CAMBODIA

## AND PRESIDENT OF THE ASIAN PARLIAMENTARY ASSEMBLY (APA)

## AT CLOSING CEREMONY OF THE 8TH PLENARY SESSION OF APA

## 11 DECEMBER 2015, SOKHA HOTEL AND RESIDENCE

- **Honorable Heads and Members of APA Member Parliaments**
- **Honorable Observer Parliaments and Partner Organizations of APA**
- **Excellencies, National and International Distinguished Guests, Ladies and Gentlemen**

1. On behalf of the National Assembly of Cambodia and as President of the Asian Parliamentary Assembly (APA), I strongly welcome the reports of the 8th APA Plenary Session on the results and achievements accomplished over the past four days. I am really delighted and deeply value for the utmost efforts of all Honorable Delegates contributing the great success of the Plenary.

2. Taking this opportunity, I deeply thank the Organizing Committee, the APA Secretariat and all concerned stakeholders that helped to facilitate and enable the 8th APA to go smoothly and successfully.

3. This historical event provided valuable opportunities and ideas for Cambodia and for the APA members and observer parliaments to join together to materialize a long-term, common vision representating one voice for all Asian nations.

4. I have observed that the Plenary proceeded in an atmosphere of friendship, solidarity and close cooperation among our parliaments in

Asia and synthesized ideas to be included in the resolutions and Phnom Penh Declarations.

***Honorable Delegates,***
***Excellencies, ladies and gentlemen,***

5. Regional and global peace is a key factor and prerequisite for national development. Our Cambodian people know clearly that our country experienced severe crises for almost three decades, such as internal conflicts, genocide, economic sanctions, starvation and epidemics. We also learned that the only way to address such chronic situations is Peace that comes from **"Reconciliation and Dialogue"**.

6. Based on the principles of Culture of Dialogue and Nonviolence, all conflicts can be resolved successfully and subsequently achieved success through Win-Win Policies, in which all rival factions win and benefit with no-one losing.

7. With lessons learnt from our past, the Cambodian Parliament proposed **"Promoting Peace, Reconciliation and Dialogue in Asia"** as the main theme of the $8^{th}$ APA Plenary Session to be discussed and adopted for the historical records of APA. We realize that all member countries have the common aspiration to live in peace and prosperity.

8. As Leaders of Parliaments, representing the will of people in the region, we have a moral obligation and deep responsibility to ensure security and prosperity for our nations. Parliaments are not only institutions that have roles to legislate, adopt laws and scrutinize their implementation. Legislative outputs also represent the heart and soul of the people. Fulfillment of all these tasks clearly demonstrates the legal power towards the Executive bodies in its effective implementation. Accomplishing these main targets requires close and effective cooperation between Legislative and Executive bodies.

9. Cambodia supports initiatives that adhere to resolving problems through peaceful solutionS, without the use of violence, avoiding armed confrontation and especially the strengthening of the roles of parliaments in making utmost efforts to attain reconciliation and peace in Asia.

10. In this context, on behalf of APA, I would like to encourage all APA members and all concerned stakeholders to uphold the principles of tolerance, in particular uphold culture of dialogue in addressing conflicts and paving the way for peace in the region and the world. With this spirit, we express our commitment to the Phnom Penh Declarations and to resolutions adopted by the 8th APA Plenary Session.

11. In our experiences, since Cambodia enjoys peace and positive development, we actively cooperate and collaborate with the UN to maintain security in the world, especially to continue our strong effort and determination to realize the Sustainable Development Goals (SDGs) 2016-2030.

12. When a country enjoys peace, people will have a secure life and prosperity. Peace brings everything for all human kind in the world to live in harmony and dignity.

13. I am confident that the positive results of the 8th APA will bring peace and prosperity to all people in Asia.

14. Finally, I wish all the best wishes to Honorable Delegates, Excellencies and distinguished participants and encourage their respective governments to consider the implementation of these resolutions for the benefit of our nations.

**I declare the 8th Plenary Session of the Asian Parliamentary Assembly closed.**

**Thank you very much**

# សុន្ទរកថា"បិទ"

## សម្តេចអគ្គមហាពញាចក្រី ហេង សំរិន
## ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
## និងជាប្រធានសភាអាស៊ី(អេភីអេ)លើកទី៨ក្នុងឱកាសបិទ
## មហាសន្និបាតលើកទី៨របស់សភាតំបន់អាស៊ី-អេភីអេ

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែធ្នូ ឆ្នាំ២០១៥ ម៉ោង ០៥:៣០នាទីល្ងាច
នៅសណ្ឋាគារសុខាភ្នំពេញ និងរ៉េស៊ីដង់

- សម្តេចឯកឧត្តមលោកជំទាវប្រធាន និងសមាជិកគណៈប្រតិភូសភានៃប្រទេសជាសមាជិកសភាតំបន់អាស៊ីគណៈប្រតិភូសភានៃប្រទេសអ្នកសង្កេតការណ៍ និងអង្គការដៃគូនៃសភាតំបន់អាស៊ី
- ឯកឧត្តម លោកជំទាវ ភ្ញៀវជាតិ ភ្ញៀវអន្តរជាតិ លោកស្រីអស់លោក ជាទីរាប់អាន!

**១**.ក្នុងនាមសភាកម្ពុជានិងក្នុងនាមសភាតំបន់អាស៊ីអេភីអេ ខ្ញុំសូមអបអរសាទរយ៉ាងក្រៃលែងចំពោះសេចក្តីរាយការណ៍ជាបន្តបន្ទាប់ ស្តីពីលទ្ធផលមហាសន្និបាតក្នុងរយៈពេល៤ថ្ងៃកន្លងមកនេះ។ ខ្ញុំមានទឹកចិត្តសោមនស្សរីករាយនិងសូមកោតសរសើរដ៏ស្មោះចំពោះកិច្ចខិតខំប្រឹងប្រែងយ៉ាងខ្លាំងរបស់ឯកឧត្តមលោកជំទាវលោកលោក

ស្រីទាំងអស់ក្នុងការធ្វើឲ្យសម្រេចបាននូវសមិទ្ធផលដ៏មហិមានេះ។

២.ឆ្លៀតឱកាសដ៏ប្រសើរនេះខ្ញុំសូមសម្តែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះគណៈកម្មការរៀបចំមហាសន្និបាតអគ្គលេខាធិការដ្ឋាន**អេភីអេ** និងគ្រប់ផ្នែកពាក់ព័ន្ធទាំងអស់ដែលជួយសម្របសម្រួល និងបង្កលក្ខណៈងាយស្រួលឲ្យមហាសន្និបាតលើកទី៨ របស់ APA ប្រព្រឹត្តទៅដោយរលូន និងប្រកបដោយជោគជ័យ។

៣.ព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្ររបស់ **អេភីអេ** បានផ្តល់ឱកាសដ៏ថ្លៃថ្លា និងគោលគំនិតល្អៗសម្រាប់ប្រទេសកម្ពុជា ក៏ដូចជាបណ្តាប្រទេសសមាជិក **អេភីអេ** ប្រទេសអ្នកសង្កេតការណ៍ស្លាបនារួមគ្នានូវទស្សនៈ វិស័យវែងឆ្ងាយដែលជាតំណាងឲ្យសម្លេងតែមួយរបស់ប្រជាជាតិអាស៊ី។

៤.ខ្ញុំសង្កេតឃើញថា អង្គមហាសន្និបាតបានដំណើរការទៅយ៉ាង សកម្មក្នុងបរិយាកាសមិត្តភាពសាមគ្គីភាពសហប្រតិបត្តិការយ៉ាងជិតស្និទ្ធរវាងតំណាងអង្គការនីតិប្បញ្ញត្តិនៅទ្វីបអាស៊ី និងបានសំយោគនូវបញ្ញាញាណប្រកបដោយភាពទទួលខុសត្រូវខ្ពស់ដើម្បីបញ្ជ្រាបបញ្ចូលទៅក្នុងសេចក្តីថ្លែងការណ៍ភ្នំពេញ និងសេចក្តីសម្រេចនានា។

*ឯកឧត្តម លោកជំទាវលោក លោកស្រី!*

**៥**.សន្តិភាពនៅក្នុងតំបន់និងសកលលោក គឺជាកត្តាចំបងចាំបាច់សម្រាប់អភិវឌ្ឍប្រទេសជាតិ។ប្រជាជនកម្ពុជាយើងខ្ញុំដឹងយ៉ាងច្បាស់ថា មាតុភូមិរបស់ខ្លួនធ្លាប់បានឆ្លងកាត់នូវវិបត្តិធ្ងន់ធ្ងរអស់ ជិត៣ទសវត្សរ៍ដូចជាសង្គ្រាមផ្ទៃក្នុងអំពើប្រល័យពូជសាសន៍ទណ្ឌកម្មសេដ្ឋកិច្ច គ្រោះទុរ្ភិក្សជំងឺរាតត្បាតជាដើម។ យើងក៏ដឹងច្បាស់ដែរថាអ្វីដែលអាចស្រោចស្រង់ស្ថានភាពដ៏ធ្ងន់ធ្ងរនេះឡើងវិញបានគឺសន្តិភាពដែលកើតចេញពី**“ ការផ្សះផ្សា និងសន្ទនា”** ។

**៦**. អាស្រ័យដោយការប្រើប្រាស់វប្បធម៌សន្ទនានិងការប្រកាន់យកគោលការណ៍អហិង្សាទើបរាល់បញ្ហាប្រឈម ត្រូវបានដោះស្រាយដោយជោគជ័យជាបន្តបន្ទាប់តាមរយៈនយោបាយឈ្នះឈ្នះ ពោលគឺគ្រប់ភាគីបដិបក្ខទទួលបានជ័យជំនះទាំងអស់គ្នា។

**៧**.ផ្ដើមចេញពីមេរៀនអតីតកាលរបស់ខ្លួន ទើបសភាកម្ពុជាសម្រេចជ្រើសរើសយកបញ្ហាស្នូលគឺ**“ ការជំរុញសន្តិភាពការផ្សះផ្សានិងការសន្ទនាក្នុងតំបន់អាស៊ី”** មកធ្វើជាប្រធានបទសម្រាប់អង្គមហាសន្និបាតលើកទី៨ដើម្បីធ្វើជាមូលដ្ឋានក្នុងការត្រិះរិះពិភាក្សា អនុម័តទុកជាឯកសារប្រវត្តិសាស្ត្រសម្រាប់**អេភីអេ**ព្រោះយើងដឹងថាប្រទេស

សមាជិកទាំងអស់សុទ្ធតែមានបំណងប្រាថ្នាដ៏ពិសិដ្ឋគឺការចង់បាន សុខសន្តិភាពដូចៗគ្នា។

**៨**.សម្រាប់យើងទាំងអស់គ្នាដែលជាថ្នាក់ដឹកនាំសភា និង តំណាងឲ្យឆន្ទៈរបស់ប្រជាពលរដ្ឋនៅក្នុងតំបន់យើងមានកាតព្វកិច្ច ស្នូលដ៏ធ្ងន់ធ្ងរ និងមានការទទួលខុសត្រូវខ្ពស់ក្នុងការធានាឲ្យបាននូវ សន្តិសុខជូនប្រជាជាតិរបស់ខ្លួន។បើទោះបីជាសភាគ្រាន់តែជាអ្នក តាក់តែង និងអនុម័តច្បាប់និងជាអ្នកត្រួតពិនិត្យលើដំណើរការការ អនុវត្តតែប៉ុណ្ណោះក៏ដោយប៉ុន្តែសមិទ្ធផលការងារនីតិកម្មគឺជា និមិត្តរូបនៃដួងចិត្តរបស់ប្រជាជនយើង។កិច្ចការទាំងនេះមានអំណាច ផ្លូវច្បាប់ចំពោះស្ថាប័ននីតិប្រតិបត្តិក្នុងការទទួលយកទៅអនុវត្តប្រកប ដោយប្រសិទ្ធភាព។ដូច្នេះដើម្បីសម្រេចឲ្យបានគោលដៅធំៗទាំងនេះ យើងត្រូវតែមានកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធនិងប្រកបដោយ ប្រសិទ្ធភាពរវាងស្ថាប័ននីតិបញ្ញត្តិ និងនីតិប្រតិបត្តិ។

**៩**.កម្ពុជាសូមគាំទ្រនូវរាល់គំនិតផ្តួចផ្តើមទាំងឡាយណា សំដៅរកដំណោះស្រាយសន្តិភាពដោយអហិង្សា ជៀសវៀងការ ប្រឈមមុខគ្នាដោយអាវុធ និងជាពិសេសពង្រីកតួនាទីសភាក្នុងកិច្ច ខិតខំប្រឹងប្រែងក្នុងការផ្សះផ្សានិងស្វែងរកសន្តិភាពក្នុងតំបន់អាស៊ី។

**១០**. ក្នុងបរិបទនេះក្នុងនាមសភាតំបន់អាស៊ី-**អេភីអេ**ខ្ញុំសូមស្នើ ឲ្យសភានៃប្រទេសជាសមាជិក**អេភីអេ**និងដៃគូពាក់ព័ន្ធទាំងអស់ប្រកា ន់យកនូវភាពអត់ធ្មត់ ជាពិសេសអនុវត្តឲ្យបាននូវកិច្ចសន្ទនាក្នុងតំបន់

អាស៊ីយើងនេះក្នុងការដោះស្រាយនិងត្រួសត្រាយផ្លូវដើម្បីសន្តិភាព សម្រាប់តំបន់និងសកលលោកទាំងមូល។

សេចក្តីថ្លែងការណ៍ភ្នំពេញ ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ និងសេចក្តីសម្រេចនានារបស់អេភីអេ ដែលមហាសន្និបាតបានអនុម័តឱឡារិកគប្បីត្រូវគោរពទាំងអស់គ្នា។

**១១**.ជាបទពិសោធន៍ ដោយសារតែប្រទេសមានសុខសន្តិភាព និងការរីកចម្រើនជាវិជ្ជមាន កម្ពុជាបានសហការយ៉ាងសកម្មជាមួយអង្គការសហប្រជាជាតិក្នុងការចូលរួមថែរក្សាសន្តិសុខនៅក្នុងពិភពលោកជាពិសេសការបន្តខិតខំ និងការប្តេជ្ញាចូលរួមសម្រេចឲ្យបានគោលដៅអភិវឌ្ឍប្រកបដោយនិរន្តរភាព(អេសឌីជី)សម្រាប់ឆ្នាំ ២០១៦-២០៣០។

**១២**.ប្រទេសមានសន្តិភាព ទើបប្រជាពលរដ្ឋកាន់តែមានភាពកក់ក្តៅក្នុងការរស់នៅ និងប្រកបការងារផ្សេងៗបានកាន់តែទូលំទូលាយ។សន្តិភាពនាំមកនូវអ្វីៗគ្រប់យ៉ាងសម្រាប់មនុស្សលោករស់នៅក្នុងភាពសុខដុមរម្យនា និងសេចក្តីថ្លៃថ្នូរ។

**១៣**.ខ្ញុំសង្ឃឹមយ៉ាងមុតមាំថាលទ្ធផលជាវិជ្ជមានរបស់មហាសន្និបាតសភាអាស៊ីលើកទី៨នេះ

ពិតជានាំមកនូវសុខសន្តិភាពវិបុលភាពនិងភាពសម្បូណ៌រុងរឿង ដល់ពលរដ្ឋអាស៊ី។

**១៤**.ជាទីបញ្ចប់នេះខ្ញុំសូមប្រសិទ្ធពរជូនឯក**ឧត្តម** **លោកជំទាវ និងគណៈប្រតិភូទាំងអស់ទទួលយកនូវសមិទ្ធផលដ៏ត្រចះត្រចង់នេះ** សម្រាប់ជាគុណប្រយោជន៍របស់ប្រជាជាតិយើងទាំងអស់គ្នា។

**ខ្ញុំសូមប្រកាសបិទមហាសន្និបាតលើកទី៨ របស់សភាតំបន់អាស៊ី-អេភីអេចាប់ពីពេលនេះតទៅ៕**

សូមអរគុណ!